**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ [illegible] សហវ.ក

# ប្រកាស

## ស្តីពី

## ការលុបគណនី ការបង្កើតលេខកូដតាមអតិរេក ការកែសម្រួលឈ្មោះ និងការបង្កើតបន្ថែមគណនី និងអនុគណនីក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា

មួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៩ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ១៧១ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ ស្តីពីការកែសម្រួល និងការបង្កើតបន្ថែមគណនី និងអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកានៃប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

១.ត្រូវបានលុបគណនីដែលមានឈ្មោះ “មូលនិធិបម្រុង” (លេខ ៧៥១០) ពីមាតិកាចំណូលថវិកា ដែលត្រូវបានដាក់ឱ្យអនុវត្តដោយប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

២.ត្រូវបានបង្កើតលេខកូដ និងឈ្មោះនៅក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាមានដូចខាងក្រោម÷

-លេខកូដ ០០១ មានឈ្មោះ “អតិរេកថវិកាប្រចាំឆ្នាំ”

-លេខកូដ ០០២ មានឈ្មោះ “ហិរញ្ញប្បទានដោយប្រភពអតិរេក”។

**ប្រការ២.-**

ត្រូវបានកែសម្រួលឈ្មោះ និងបង្កើតបន្ថែមគណនី និងអនុគណនី នៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈដែលមានឈ្មោះ និងលេខសម្គាល់ដូចខាងក្រោម÷

១.កែសម្រួលឈ្មោះគណនី "ប្រាក់បញ្ញើជំនួយនៅធនាគារជាតិនៃកម្ពុជា ជាប្រាក់រៀល" (លេខ ១១០២) ទៅជាឈ្មោះ "ប្រាក់បញ្ញើជំនួយនិងហិរញ្ញប្បទានផ្សេងៗនៅធនាគារជាតិនៃកម្ពុជា ជាប្រាក់រៀល" (លេខ ១១០២) ដែលស្ថិតនៅក្នុងជំពូក"ធនាគារ" (លេខ ១១) ក្នុងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

២.កែសម្រួលឈ្មោះគណនី "ប្រាក់បញ្ញើជំនួយនៅធនាគារជាតិនៃកម្ពុជា ជាប្រាក់ដុល្លារអាមេរិក" (លេខ ១១០៣) ទៅជាឈ្មោះ "ប្រាក់បញ្ញើជំនួយនិងហិរញ្ញប្បទានផ្សេងៗ នៅធនាគារជាតិនៃកម្ពុជា ជាប្រាក់ដុល្លារអាមេរិក" (លេខ ១១០៣) ដែលស្ថិតនៅក្នុងជំពូក "ធនាគារ" (លេខ ១១) ក្នុងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

៣.កែសម្រួលឈ្មោះអនុគណនី "ប្រាក់បញ្ញើរបស់បេឡាជាតិសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល-តាវកាលិកនៅរតនាគារ" (លេខ ១២០៥៣) ទៅជាឈ្មោះ "ប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គម នៅរតនាគារ សម្រាប់តាវកាលិករបស់អតីតមន្ត្រីរាជការស៊ីវិល" (លេខ ១២០៥៣) ដែលស្ថិតនៅក្នុងគណនី "ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារ" (លេខ ១២០៥) ក្នុងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

៤.កែសម្រួលឈ្មោះអនុគណនី "ប្រាក់បញ្ញើរបស់បេឡាជាតិអតីតយុទ្ធជន-តាវកាលិកនៅរតនាគារ" (លេខ ១២០៥៤) ទៅជាឈ្មោះ "ប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមនៅរតនាគារសម្រាប់តាវកាលិករបស់អតីតយុទ្ធជន" (លេខ ១២០៥៤) ដែលស្ថិតនៅក្នុងគណនី "ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារ" (លេខ ១២០៥) ក្នុងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

៥.កែសម្រួលឈ្មោះជំពូក "បុគ្គលិកត្រូវសង" (លេខ ៤២) ទៅជាឈ្មោះ "ប្រាក់បៀវត្ស ប្រាក់កម្រៃ លាភការ ប្រាក់ឧបត្ថម្ភ និងជំនួយសង្គមត្រូវសង" (លេខ ៤២) ក្នុងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

៦.កែសម្រួលឈ្មោះអនុគណនី "ប្រាក់បញ្ញើរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល" (លេខ ៤៤០៥៣) ទៅជាឈ្មោះ "ប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមសម្រាប់តាវកាលិករបស់អតីតមន្ត្រីរាជការស៊ីវិល" (លេខ ៤៤០៥៣) ដែលស្ថិតនៅក្នុងគណនី "ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល" (លេខ ៤៤០៥) ក្នុងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

៧.កែសម្រួលឈ្មោះអនុគណនី "ប្រាក់បញ្ញើរបស់បេឡាជាតិអតីតយុទ្ធជន-តាវកាលិក" (លេខ ៤៤០៥៤) ទៅជាឈ្មោះ "ប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមសម្រាប់តាវកាលិករបស់អតីតយុទ្ធជន" (លេខ ៤៤០៥៤) ដែលស្ថិតនៅក្នុងគណនី "ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល" (លេខ ៤៤០៥) ក្នុងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

៨.កែសម្រួលឈ្មោះគណនី "ឧបត្ថម្ភលើតាវកាលិក" (លេខ ៦២០៧) ទៅជាឈ្មោះ "ឧបត្ថម្ភតាវកាលិករបស់អតីតមន្ត្រីរាជការស៊ីវិល" (លេខ ៦២០៧) ដែលស្ថិតនៅក្នុងជំពូក "អត្ថប្រយោជន៍សង្គម" (លេខ ៦២) ក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

៩.កែសម្រួលឈ្មោះអនុគណនី "ឧបត្ថម្ភធនដល់ក្រសួង-ស្ថាប័ន" (លេខ ៦៥០១៤) ទៅជាឈ្មោះ "ឧបត្ថម្ភកធន ឬ បែងចែកចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលជូនក្រសួង ស្ថាប័ន" (លេខ ៦៥០១៤) ដែលស្ថិតនៅក្នុងគណនី "ឧបត្ថម្ភធនរវាងរដ្ឋបាលសាធារណៈ" (លេខ ៦៥០១) ក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

១០.កែសម្រួលឈ្មោះគណនី "កម្រៃប្រតិបត្តិការផ្សេងៗទៀត" (លេខ ៧៣០៦) ទៅជាឈ្មោះ "ចំណូលកាតព្វកិច្ចពីល្បែងនិងកម្រៃប្រតិបត្តិការផ្សេងៗទៀត" (លេខ ៧៣០៦) ដែលស្ថិតនៅក្នុងជំពូក "ផលទុនពីការលក់

ជួលទ្រព្យសម្បត្តិ និងសេវា" (លេខ ៧៣) ក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**១១.**កែសម្រួលឈ្មោះអនុគណនី "ចំណូលពីកាតព្វកិច្ចកាស៊ីណូ" (លេខ ៧៣០៦១) ទៅជាឈ្មោះ "ចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូ" (លេខ ៧៣០៦១) ដែលស្ថិតនៅក្នុងគណនី "ចំណូលកាតព្វកិច្ចពីល្បែង និងកម្រៃប្រតិបត្តិការផ្សេងៗទៀត" (លេខ ៧៣០៦) ក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**១២.**កែសម្រួលឈ្មោះអនុគណនី "ចំណូលពីកាតព្វកិច្ចឆ្នោត" (លេខ ៧៣០៦២) ទៅជាឈ្មោះ "ចំណូលកាតព្វកិច្ចពីល្បែងផ្សងសំណាង" (លេខ ៧៣០៦២) ដែលស្ថិតនៅក្នុងគណនី "ចំណូលកាតព្វកិច្ចពីល្បែងនិងកម្រៃប្រតិបត្តិការផ្សេងៗទៀត" (លេខ ៧៣០៦) ក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**១៣.**កែសម្រួលឈ្មោះអនុគណនី "ចំណូលពីកាតព្វកិច្ចល្បែងភ្នាល់ផ្សេងៗ" (លេខ ៧៣០៦៣) ទៅជាឈ្មោះ "ចំណូលកាតព្វកិច្ចពីល្បែងភ្នាល់" (លេខ ៧៣០៦៣) ដែលស្ថិតនៅក្នុងគណនី "ចំណូលកាតព្វកិច្ចពីល្បែង និងកម្រៃប្រតិបត្តិការផ្សេងៗទៀត" (លេខ ៧៣០៦) ក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**១៤.**បង្កើតបន្ថែមអនុគណនី "ប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមនៅរតនាគារ សម្រាប់កម្មវិធីជាតិជំនួយសង្គម" (លេខ ១២០៥៥) ដែលស្ថិតនៅក្នុងគណនី "ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅរតនាគារ" (លេខ ១២០៥) ក្នុងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**១៥.**បង្កើតបន្ថែមអនុគណនី "អប្បហារមូលបត្ររដ្ឋ" (លេខ ១៥០៦៣) ដែលស្ថិតនៅក្នុងគណនី "ឥណាយិកផ្សេងៗ" (លេខ ១៥០៦) ក្នុងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**១៦.**បង្កើតបន្ថែមគណនី "មូលនិធិបម្រុងសម្រាប់ហានិភ័យ" (លេខ ៣០០៥) ដែលស្ថិតនៅក្នុងជំពូក "មូលធននិងធនបំរុង" (លេខ ៣០) ក្នុងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**១៧.**បង្កើតបន្ថែមគណនី "ប្រាក់ត្រូវទូទាត់ជូនអង្គភាពផ្សេងៗ" (លេខ ៤០០៦) ស្ថិតនៅក្នុងជំពូក "គណនីត្រូវសង" (លេខ ៤០) ក្នុងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**១៨.**បង្កើតបន្ថែមអនុគណនី "តាវកាលិកត្រូវសងមន្ត្រីសាធារណៈ" (លេខ ៤២០៣៣) ដែលស្ថិតនៅក្នុងគណនី "តាវកាលិកត្រូវសង" (លេខ ៤២០៣) ក្នុងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**១៩.**បង្កើតបន្ថែមអនុគណនី "តាវកាលិកត្រូវសងកម្មករនិងនិយោជិត" (លេខ ៤២០៣៤) ដែលស្ថិតនៅក្នុងគណនី "តាវកាលិកត្រូវសង" (លេខ ៤២០៣) ក្នុងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**២០.**បង្កើតបន្ថែមគណនី "ជំនួយសង្គមត្រូវសង" (លេខ ៤២០៤) ដែលស្ថិតនៅក្នុងជំពូក "ប្រាក់បៀវត្សប្រាក់កម្រៃ លាភការ ប្រាក់ឧបត្ថម្ភនិងជំនួយសង្គម ត្រូវសង" (លេខ ៤២) ក្នុងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**២១.**បង្កើតបន្ថែមអនុគណនី "ប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមសម្រាប់ថវិកាជំនួយសង្គម" (លេខ ៤៤០៥៥) ដែលស្ថិតនៅក្នុងគណនី "ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល" (លេខ ៤៤០៥) ក្នុងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**២២.** បង្កើតបន្ថែមអនុគណនី "ឧបត្ថម្ភកម្មវិធីជាតិជំនួយសង្គម" (លេខ ៦២០១៥) ដែលស្ថិតនៅក្នុងគណនី "អត្ថប្រយោជន៍របបសន្តិសុខសង្គម" (លេខ ៦២០១) ក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**២៣.** បង្កើតបន្ថែមគណនី "ឧបត្ថម្ភតាវកាលិករបស់អតីតយុទ្ធជន" (លេខ ៦២០៨) ដែលស្ថិតនៅក្នុងជំពូក "អត្ថប្រយោជន៍សង្គម" (លេខ ៦២) ក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**២៤.** បង្កើតបន្ថែមគណនី "ឧបត្ថម្ភតាវកាលិកលើហានិភ័យការងាររបស់មន្ត្រីសាធារណៈ កម្មករ និងនិយោជិត" (លេខ ៦២០៩) ដែលស្ថិតនៅក្នុងជំពូក "អត្ថប្រយោជន៍សង្គម" (លេខ ៦២) ក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**២៥.** បង្កើតបន្ថែមគណនី "ឧបត្ថម្ភតាវកាលិកលើការថែទាំសុខភាពរបស់មន្ត្រីសាធារណៈ កម្មករ និងនិយោជិត" (លេខ ៦២១០) ដែលស្ថិតនៅក្នុងជំពូក "អត្ថប្រយោជន៍សង្គម" (លេខ ៦២) ក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**២៦.** បង្កើតបន្ថែមគណនី "ឧបត្ថម្ភតាវកាលិកលើសោធនរបស់កម្មករ និងនិយោជិត" (លេខ ៦២១១) ដែលស្ថិតនៅក្នុងជំពូក "អត្ថប្រយោជន៍សង្គម" (លេខ ៦២) ក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**២៧.** បង្កើតបន្ថែមគណនី "ឧបត្ថម្ភកញ្ចប់គ្រួសារ" (លេខ ៦២១២) នៃជំពូក "អត្ថប្រយោជន៍សង្គម" (លេខ ៦២) ក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

**ប្រការ៣.- ប្រព្រឹត្តិកម្មនៃលេខកូដ គណនី និងអនុគណនី÷**

**១.** លេខកូដមានឈ្មោះ "អតិរេកថវិកាប្រចាំឆ្នាំ" មានលេខសម្គាល់ ០០១ ប្រើសម្រាប់តាងតួលេខអតិរេក នៅពេលគ្រោងថវិកាក្នុងករណីសរុបចំណូល (ចំណូលចរន្ត និងចំណូលវិនិយោគ) ធំជាងសរុបចំណាយ (ចំណាយចរន្ត និងចំណាយវិនិយោគ)។ លេខកូដនេះ ត្រូវបានបង្ហាញនៅក្នុងផ្នែកចំណាយនៃគម្រោងថវិកាដើម្បីមានតុល្យភាពរវាងសរុបចំណូល និងសរុបចំណាយ។ ក៏ប៉ុន្តែ ពុំគិតបញ្ចូលទៅក្នុងទឹកប្រាក់ចំណាយថវិកាទេ។

**២.** លេខកូដមានឈ្មោះ "ហិរញ្ញប្បទានដោយប្រភពអតិរេក" មានលេខសម្គាល់ ០០២ ប្រើសម្រាប់តាងតួលេខអតិរេកដែលត្រូវប្រើប្រាស់ជាហិរញ្ញប្បទានបន្ថែមលើចំណូលថវិកា (ចំណូលចរន្ត និងចំណូលវិនិយោគ) ដើម្បីបានជាធនធានសរុបសម្រាប់ធានាចំណាយសរុបនៅក្នុងគម្រោងថវិកា។

**បញ្ជាក់÷**
- តួលេខនៃអតិរេកដែលជាហិរញ្ញប្បទានក្នុងឆ្នាំ ដែលជាចំណែកនៃអតិរេកថវិកា (លេខកូដ ០០២) ពុំមានប្រតិបត្តិការ និងការកត់ត្រាជាចំណូលថវិកាទេ។
- សាច់ប្រាក់នៃអតិរេកថវិកាដែលត្រូវប្រើប្រាស់ជាហិរញ្ញប្បទាន មាននៅក្នុងគណនីនៅធនាគារ ឬ នៅក្នុងគណនីប្រាក់បញ្ញើនៅរតនាគារ ដែលបដិភាគនឹងគណនីយោងជាថ្មី និង/ឬ គណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៣.** គណនី "ប្រាក់បញ្ញើជំនួយ និងហិរញ្ញប្បទានផ្សេងៗ នៅធនាគារជាតិនៃកម្ពុជាជាប្រាក់រៀល" (លេខ ១១០២) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលក្នុងគណនីនៅធនាគារ ដែលបានទទួលពីជំនួយ អំណោយ និង

ហិរញ្ញប្បទានពីប្រភពផ្សេងៗ ដូចជាការបោះផ្សាយមូលបត្រ...។ ការកត់ត្រាតួលេខចលនានៃគណនីនេះ ដោយយោងតាមប្រកាសឥណទាន ឬ បណ្ណបង់ប្រាក់ ឬ ប្រកាសឥណពន្ធ ឬ បណ្ណដកប្រាក់ ឬ របាយការណ៍របស់ធនាគារជាតិនៃកម្ពុជា។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូល ដែលបានទទួលដោយបង់ជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ បង្វែរ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណាយ យោងតាមរយៈអាណត្តិបើកប្រាក់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- កត់ត្រាចំនួនទឹកប្រាក់ចំណាយដោយផ្ទេរទៅគណនីផ្សេង យោងតាមការសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើដែលបានទទួលពីជំនួយ ឬ អំណោយ ឬ ហិរញ្ញប្បទានពីប្រភពផ្សេង កំពុងមាននៅធនាគារជាតិនៃកម្ពុជា។

**បញ្ជាក់** ÷ - គណនីលេខ ១១០២ ចែកជាអនុគណនីសម្រាប់ឆ្លុះបញ្ចាំងទៅនឹងគណនីទាំងឡាយ ដែលមាននៅធនាគារជាតិនៃកម្ពុជា

- បញ្ជីរាយឈ្មោះ និងលេខអនុគណនីត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ

- អនុគណនីទាំងឡាយនៃគណនីនេះ មានប្រតិបត្តិការបញ្ច្រាសនឹងគណនីនៅធនាគារជាតិនៃកម្ពុជា។

**៤.**គណនី "ប្រាក់បញ្ញើជំនួយនិងហិរញ្ញប្បទានផ្សេងៗនៅធនាគារជាតិនៃកម្ពុជា ជាប្រាក់ដុល្លារអាមេរិក" (លេខ ១១០៣) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលក្នុងគណនីនៅធនាគារ ដែលបានទទួលពីជំនួយអំណោយ និងហិរញ្ញប្បទានពីប្រភពផ្សេងៗ ដូចជាការបោះផ្សាយមូលបត្រ...។ ការកត់ត្រាតួលេខចលនានៃគណនីនេះ ដោយយោងតាមប្រកាសឥណទាន ឬ បណ្ណបង់ប្រាក់ ឬ ប្រកាសឥណពន្ធ ឬ បណ្ណដកប្រាក់ ឬ របាយការណ៍របស់ធនាគារជាតិនៃកម្ពុជា។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលដោយបង់ជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ បង្វែរ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណាយតាមរយៈអាណត្តិបើកប្រាក់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- កត់ត្រាចំនួនទឹកប្រាក់ចំណាយដោយផ្ទេរទៅគណនីផ្សេង យោងតាមការសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើដែលបានទទួលពីជំនួយ ឬ ពីអំណោយ ឬ ពីហិរញ្ញប្បទានពីប្រភពផ្សេងកំពុងមាននៅធនាគារជាតិនៃកម្ពុជា។

**បញ្ជាក់** ÷ - គណនីលេខ ១១០៣ ចែកជាអនុគណនីសម្រាប់ឆ្លុះបញ្ចាំងទៅនឹងគណនីទាំងឡាយដែលមាននៅធនាគារជាតិនៃកម្ពុជា

- បញ្ជីរាយឈ្មោះនិងលេខអនុគណនីត្រូវរៀបចំដោយអគ្គនាយកដ្ឋានរតនាគារជាតិ

- អនុគណនីទាំងឡាយនៃគណនីនេះមានប្រតិបត្តិការបញ្ច្រាសនឹងគណនីនៅធនាគារជាតិនៃកម្ពុជា។

**៥.**គណនី "ប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមនៅរតនាគារសម្រាប់តាវកាលិករបស់អតីតមន្ត្រីរាជការស៊ីវិល" (លេខ ១២០៥៣) ប្រើសម្រាប់កត់ត្រានៅមូលនិធិជាតិជំនួយសង្គមនូវចំនួនទឹកប្រាក់ចំណូល ចំណាយតាវកាលិករបស់អតីតមន្ត្រីរាជការស៊ីវិល។

ការកត់ត្រា÷

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ចំណូលរបស់មូលនិធិជាតិជំនួយសង្គមនៅរតនាគារ សម្រាប់តាវកាលិករបស់មន្ត្រីរាជការស៊ីវិល

- កត់ត្រាចំនួនទឹកប្រាក់សំណៃសចំណាយដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់តាវកាលិកដែលបានដកពីគណនីរបស់មូលនិធិជាតិជំនួយសង្គម

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមសម្រាប់តាវកាលិករបស់អតីតមន្ត្រីរាជការស៊ីវិលដែលកំពុងមាននៅរតនាគារ។

**បញ្ជាក់÷** គណនីលេខ ១២០៥៣ កត់ត្រាឆ្លុះបញ្ចាំងបញ្ច្រាសជាមួយអនុគណនីលេខ ៤៤០៥៣ នៅរតនាគារ។

**៦.** អនុគណនី "ប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមនៅរតនាគារសម្រាប់តាវកាលិករបស់អតីតយុទ្ធជន" (លេខ ១២០៥៤) ប្រើសម្រាប់កត់ត្រានៅមូលនិធិជាតិជំនួយសង្គមនូវចំនួនទឹកប្រាក់ចំណូល ចំណាយតាវកាលិករបស់អតីតយុទ្ធជន។

ការកត់ត្រា÷

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ចំណូលរបស់មូលនិធិជាតិជំនួយសង្គមនៅរតនាគារ សម្រាប់តាវកាលិករបស់អតីតយុទ្ធជន

- កត់ត្រាចំនួនទឹកប្រាក់សំណៃសចំណាយដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់តាវកាលិក ដែលបានដកពីគណនីប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមនៅរតនាគារ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមសម្រាប់តាវកាលិករបស់អតីតយុទ្ធជន ដែលកំពុងមាននៅរតនាគារ។

**បញ្ជាក់ ÷** គណនីលេខ ១២០៥៤ កត់ត្រាឆ្លុះបញ្ចាំងបញ្ច្រាសជាមួយអនុគណនីលេខ ៤៤០៥៤ នៅរតនាគារ។

**៧.** អនុគណនី "ប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមនៅរតនាគារសម្រាប់កម្មវិធីជំនួយសង្គម" (លេខ ១២០៥៥) ប្រើសម្រាប់កត់ត្រានៅមូលនិធិជាតិជំនួយសង្គមនូវចំនួនទឹកប្រាក់ចំណូល ចំណាយប្រាក់បញ្ញើនៅរតនាគារសម្រាប់ការឧបត្ថម្ភកម្មវិធីជំនួយសង្គមផ្សេងៗ តាមគោលការណ៍ ឬ លិខិតបទដ្ឋាន និងលក្ខខណ្ឌដែលបានកំណត់។

ការកត់ត្រា÷

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ចំណូលនៃគណនីប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គម នៅរតនាគារសម្រាប់កម្មវិធីជំនួយសង្គម

- កត់ត្រាចំនួនទឹកប្រាក់សំណៃសចំណាយដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ ដែលមូលនិធិជាតិជំនួយសង្គមបានចំណាយពីគណនីប្រាក់បញ្ញើនៅរតនាគារ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមសម្រាប់កម្មវិធីជំនួយសង្គមដែលកំពុងមាននៅរតនាគារ។

**បញ្ជាក់ ÷** គណនីលេខ ១២០៥៥ ប្រើនៅក្នុងកិច្ចបញ្ជិកាគណនេយ្យនៅមូលនិធិជាតិជំនួយសង្គម ហើយឆ្លុះបញ្ចាំងបញ្ច្រាសជាមួយអនុគណនីលេខ ៤៤០៥៥ នៅរតនាគារ។

៨.អនុគណនី "អប្បហារមូលបត្ររដ្ឋ" (លេខ ១៥០៦៣) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់អប្បហារដែលបានផ្តល់ទៅបរិវិសករដែលជាអ្នកជាវមូលបត្ររដ្ឋ។ តួលេខអប្បហាររដ្ឋដែលបានផ្តល់នោះ រង់ចាំជម្រះទូទាត់ជាចំណាយថវិកា។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់អប្បហារមូលបត្ររដ្ឋ ដែលបានផ្តល់

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់អប្បហារមូលបត្ររដ្ឋ ដែលបានទូទាត់ជម្រះជាចំណាយថវិកា

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់អប្បហារមូលបត្ររដ្ឋបានផ្តល់និងប្តូកបន្តហើយពុំទាន់បានទូទាត់ជម្រះ។

**បញ្ជាក់** ÷ - សមតុល្យរបស់គណនី ១៥០៦៣ អាចយោងទៅការិយបរិច្ឆេទក្រោយ

- ការទូទាត់ជម្រះទូទាត់សមតុល្យគណនីនេះ នៅការិយបរិច្ឆេទដែលបានទូទាត់ប្រាក់ដើមនៃមូលបត្រដែលបរិវិសករបានជាវ (តម្លៃចារឹកនាម)។

៩.គណនី "មូលនិធិបម្រុងសម្រាប់ហានិភ័យ" (លេខ ៣០០៥) ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់នៃមូលនិធិបម្រុងសម្រាប់ហានិភ័យផ្សេងៗ ដែលផ្ទេរពីគណនីយោងជាថ្មី ឬ ពីគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ការកត់ត្រា

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់នៃមូលនិធិបំរុងសម្រាប់ហានិភ័យ ដែលបានប្រើប្រាស់

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់នៃមូលនិធិបំរុងសម្រាប់ហានិភ័យដែលបានបង្កើត ឬ បានបង្កើនដោយផ្ទេរពីគណនីយោងជាថ្មី និង/ឬ ពីគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់នៃមូលនិធិបំរុងសម្រាប់ហានិភ័យ ដែលពុំទាន់ប្រើប្រាស់។

**បញ្ជាក់** ÷ ចំនួនទឹកប្រាក់មូលនិធិបំរុងសម្រាប់ហានិភ័យធានាដោយសមតុល្យគណនីនៅធនាគារ និង/ឬ នៅរតនាគារ។

១០.គណនី "ប្រាក់ត្រូវទូទាត់ជូនអង្គភាពផ្សេងៗ" (លេខ ៤០០៦) ប្រើសម្រាប់កត់ត្រានៅរតនាគារ នូវចំនួនទឹកប្រាក់ដែលត្រូវទូទាត់ជូនអង្គភាពរដ្ឋ ដែលជាអ្នកផ្តល់សេវា ឬ ការងារ ទឹកប្រាក់ត្រូវផ្តល់ជូនសហគមន៍ សមាគម គណៈកម្មាធិការ អង្គការជាតិ និងអង្គភាពផ្សេងទៀត។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានទូទាត់

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវទូទាត់

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ដែលពុំទាន់បានទូទាត់។

**បញ្ជាក់** : - គណនេយ្យករត្រូវមានបញ្ជីតាមដានលម្អិត ឬ បញ្ជីវិភាគតាមអង្គភាពនីមួយៗដែលត្រូវទទួលការទូទាត់

- គណនីនេះពុំមានតំរូវហត្ថលេខារបស់អង្គភាពនីមួយៗ ដែលត្រូវទទួលការទូទាត់។

១១.គណនី "តាវកាលិកត្រូវសង" (លេខ ៤២០៣) ប្រើសម្រាប់កត់ត្រានៅមូលនិធិជាតិជំនួយសង្គមនូវចំនួនទឹកប្រាក់តាវកាលិកដែលត្រូវសងទៅនិវត្តជនជាអតីតមន្ត្រីរាជការស៊ីវិល ជាអតីតយុទ្ធជន និងអ្នកនៅក្នុងបន្ទុក។

ការកត់ត្រា÷

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់នៃតាវកាលិក ដែលបានទូទាត់បើកផ្តល់

- កត់ត្រាចំនួនទឹកប្រាក់តាវកាលិកដែលបានបង់ជាសំណែសចំណាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់នៃតាវកាលិក ដែលត្រូវបើកផ្តល់

សមតុល្យ :   ឥណាយិក បង្ហាញចំនួនទឹកប្រាក់នៃតាវកាលិក ដែលពុំទាន់បានបើកផ្តល់។

**បញ្ជាក់ ÷**   គណនី "តាវកាលិកត្រូវសង" (លេខ ៤២០៣) ត្រូវចែកជាអនុគណនី÷ តាវកាលិកត្រូវសងអតីតមន្ត្រីរាជការស៊ីវិល (លេខ ៤២០៣១) តាវកាលិកត្រូវសងអតីយុទ្ធជន (លេខ ៤២០៣២) តាវកាលិកត្រូវសងមន្ត្រីសាធារណៈ(លេខ ៤២០៣៣) និងតាវកាលិកត្រូវសងកម្មករនិងនិយោជិត(លេខ ៤២០៣៤)។

**១២.**គណនី "ជំនួយសង្គមត្រូវសង" (លេខ ៤២០៤) ប្រើសម្រាប់កត់ត្រានៅមូលនិធិជាតិជំនួយសង្គមនូវចំនួនទឹកប្រាក់ជំនួយសង្គម ដែលត្រូវសងទៅអ្នកដែលត្រូវទទួលពីកម្មវិធីជំនួយសង្គមផ្សេងៗ ដូចជា ស្ត្រីមានផ្ទៃពោះ មនុស្សចាស់ កុមារក្នុងសាលារៀន...។

ការកត់ត្រា÷

ឥណពន្ធ  : - កត់ត្រាចំនួនទឹកប្រាក់ជំនួយសង្គម ដែលបានទូទាត់បើកផ្តល់

- កត់ត្រាចំនួនទឹកប្រាក់ជំនួយសង្គមដែលបានបង់ជាសំណៃសចំណាយ

ឥណទាន :   កត់ត្រាចំនួនទឹកប្រាក់ជំនួយសង្គមដែលត្រូវបើកផ្តល់

សមតុល្យ :   ឥណាយិក បង្ហាញចំនួនទឹកប្រាក់ជំនួយសង្គមដែលពុំទាន់បានបើកផ្តល់។

**១៣.**អនុគណនី "ប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមសម្រាប់តាវកាលិករបស់អតីតមន្ត្រីរាជការស៊ីវិល" (លេខ ៤៤០៥៣) ប្រើសម្រាប់កត់ត្រានៅរតនាគារ នូវចំនួនទឹកប្រាក់បញ្ញើតាវកាលិកសម្រាប់អតីតមន្ត្រីរាជការស៊ីវិល។

ការកត់ត្រា÷

ឥណពន្ធ  :   កត់ត្រាចំនួនទឹកប្រាក់នៃតាវកាលិក ដែលបានបើកផ្តល់

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណូលប្រាក់បញ្ញើសម្រាប់តាវកាលិកដែលបានទទួលពីក្រសួង ស្ថាប័ន

- កត់ត្រាចំនួនទឹកប្រាក់សំណៃសចំណាយដែលបានទទួល

សមតុល្យ :   ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គម នៅរតនាគារសម្រាប់តាវកាលិករបស់អតីតមន្ត្រីរាជការស៊ីវិលកំពុងមាន។

**១៤.**អនុគណនី "ប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមសម្រាប់តាវកាលិករបស់អតីតយុទ្ធជន" (លេខ ៤៤០៥៤) ប្រើសម្រាប់កត់ត្រានៅរតនាគារនូវចំនួនទឹកប្រាក់បញ្ញើតាវកាលិកសម្រាប់អតីតយុទ្ធជន។

ការកត់ត្រា÷

ឥណពន្ធ  :   កត់ត្រាចំនួនទឹកប្រាក់ដែលមូលនិធិជាតិជំនួយសង្គមបានចំណាយពីប្រាក់បញ្ញើសម្រាប់បើកផ្តល់តាវកាលិក

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណូលប្រាក់បញ្ញើសម្រាប់តាវកាលិកដែលបានពីក្រសួង ស្ថាប័ន

- កត់ត្រាចំនួនទឹកប្រាក់សំណៃសចំណាយដែលបានទទួល

សមតុល្យ :   ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមនៅរតនាគារ សម្រាប់តាវកាលិករបស់អតីតយុទ្ធជនកំពុងមាន។

**១៥.**អនុគណនី "ប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមសម្រាប់ថវិកាជំនួយសង្គម" (លេខ ៤៤០៥៥) ប្រើសម្រាប់កត់ត្រានៅរតនាគារ នូវចំនួនទឹកប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមសម្រាប់ថវិកាកម្មវិធីជំនួយសង្គម។

ការកត់ត្រា÷

ឥណពន្ធ  :   កត់ត្រាចំនួនទឹកប្រាក់ជំនួយសង្គម ដែលបានបើកផ្តល់

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណូលប្រាក់បញ្ញើសម្រាប់ជំនួយសង្គមដែលបានពីក្រសួង ស្ថាប័ន

- កត់ត្រាចំនួនទឹកប្រាក់សំណែសចំណាយដែលបានទទួល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់មូលនិធិជាតិជំនួយសង្គមនៅរតនាគារ សម្រាប់ជំនួយសង្គមកំពុងមាន។

**បញ្ជាក់** ÷ គណនីលេខ ៤៤០៥៥ ប្រើនៅក្នុងកិច្ចបញ្ជិកាគណនេយ្យរបស់រតនាគារ ហើយឆ្លុះបញ្ចាំងបញ្ច្រាសជាមួយអនុគណនីលេខ ១២០៥៥ នៅមូលនិធិជាតិជំនួសសង្គម។

**១៦.** អនុគណនី "ឧបត្ថម្ភកម្មវិធីជាតិជំនួយសង្គម" (លេខ ៦២០១៥) ប្រើសម្រាប់កត់ត្រានូវចំនួនទឹកប្រាក់ដែលក្រសួង ស្ថាប័ន បានផ្តល់ឧបត្ថម្ភធនសម្រាប់ចំណាយលើកម្មវិធីជាតិជំនួយសង្គមដែលត្រូវអនុវត្តតាមគោលការណ៍លិខិតបទដ្ឋានជាធរមាន។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការផ្តល់ឧបត្ថម្ភធនដល់មូលនិធិជាតិជំនួយសង្គម

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់សំណែសចំណាយ ដែលបានបន្ថយចំណាយថវិកានៅក្នុងឆ្នាំ

- កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**១៧.** គណនី "ឧបត្ថម្ភតាវកាលិករបស់អតីតមន្ត្រីរាជការស៊ីវិល" (លេខ ៦២០៧) ប្រើសម្រាប់កត់ត្រានៅមូលនិធិជាតិជំនួយសង្គមនូវចំនួនទឹកប្រាក់ ដែលបានចំណាយលើការបើកផ្តល់តាវកាលិក ជូននិវត្តជន ដែលជាអតីតមន្ត្រីរាជការស៊ីវិល។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា លើការបើកផ្តល់ឧបត្ថម្ភតាវកាលិក

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់សំណែសចំណាយ ដែលបានបន្ថយចំណាយថវិកានៅក្នុងឆ្នាំ

- កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិកបង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**បញ្ជាក់** ÷ គណនីលេខ ៦២០៧ ចែកចេញជាអនុគណនី÷ ឧបត្ថម្ភលើការថែទាំសុខភាព (លេខ ៦២០៧១) ឧបត្ថម្ភមាតុភាព (លេខ ៦២០៧២) ឧបត្ថម្ភមរណភាព (លេខ ៦២០៧៣) ឧបត្ថម្ភនិវត្តជន (លេខ ៦២០៧៤) ឧបត្ថម្ភជនបាត់បង់សម្បទាវិជ្ជាជីវៈឬសមត្ថភាពការងារ (លេខ ៦២០៧៥) ឧបត្ថម្ភអ្នកនៅក្នុងបន្ទុក (លេខ ៦២០៧៦) ឧបត្ថម្ភគ្រោះថ្នាក់ការងារនិងទព្វលភាព (លេខ ៦២០៧៧) និងឧបត្ថម្ភតាវកាលិកផ្សេងៗ (លេខ ៦២០៧៨)។

**១៨.** គណនី "ឧបត្ថម្ភតាវកាលិករបស់អតីតយុទ្ធជន" (លេខ ៦២០៨) ប្រើសម្រាប់កត់ត្រានៅមូលនិធិជាតិជំនួយសង្គម នូវចំនួនទឹកប្រាក់ដែលបានចំណាយថវិកាលើការបើកផ្តល់តាវកាលិកជូននិវត្តជន ដែលជាអតីតយុទ្ធជន។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការបើកផ្តល់ឧបត្ថម្ភតាវកាលិក

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់សំណែសចំណាយ ដែលបានបន្ថយចំណាយថវិកានៅក្នុងឆ្នាំ

- កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**បញ្ជាក់ ÷** គណនីលេខ ៦២០៨ ចែកចេញជាអនុគណនី÷ ឧបត្ថម្ភលើការថែទាំសុខភាព (លេខ ៦២០៨១) ឧបត្ថម្ភមាតុភាព (លេខ ៦២០៨២) ឧបត្ថម្ភមរណភាព (លេខ ៦២០៨៣) ឧបត្ថម្ភនិវត្តជន (លេខ ៦២០៨៤) ឧបត្ថម្ភជនបាត់បង់សម្បទាវិជ្ជាជីវៈឬសមត្ថភាពការងារ (លេខ ៦២០៨៥) ឧបត្ថម្ភអ្នកនៅក្នុងបន្ទុកនិវត្តជន (លេខ ៦២០៨៦) ឧបត្ថម្ភគ្រោះថ្នាក់ការងារនិងទព្វលភាព (លេខ ៦២០៨៧) និងឧបត្ថម្ភតាវកាលិកផ្សេងៗ (លេខ ៦២០៨៨)។

**១៩.** គណនី "ឧបត្ថម្ភតាវកាលិកលើហានិភ័យការងាររបស់មន្ត្រីសាធារណៈ កម្មករ និងនិយោជិត" (លេខ ៦២០៩) ប្រើសម្រាប់កត់ត្រានៅបេឡាជាតិសន្តិសុខសង្គម នូវចំនួនទឹកប្រាក់ដែលបានចំណាយថវិកា បើកផ្តល់ឧបត្ថម្ភតាវកាលិកលើហានិភ័យការងារតាមលិខិតបទដ្ឋាន និងលក្ខខណ្ឌដែលត្រូវផ្តល់ប្រាក់ឧបត្ថម្ភ។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការបើកផ្តល់ឧបត្ថម្ភតាវកាលិក

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់សំណៃសចំណាយ ដែលបានបន្ថយចំណាយថវិកានៅក្នុងឆ្នាំ

- កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**បញ្ជាក់ ÷** គណនីលេខ ៦២០៩ ចែកចេញជាអនុគណនី÷ ឧបត្ថម្ភលើការថែទាំឬព្យាបាលសុខភាព (លេខ ៦២០៩១) ឧបត្ថម្ភមរណភាព (លេខ ៦២០៩២) ឧបត្ថម្ភធនលាភ (លេខ ៦២០៩៣) ឧបត្ថម្ភវិភាជន៍ជនបាត់បង់សម្បទាវិជ្ជាជីវៈឬសមត្ថភាពការងារ (លេខ ៦២០៩៤) ឧបត្ថម្ភអ្នកនៅក្នុងបន្ទុក (លេខ ៦២០៩៥) ឧបត្ថម្ភស្តារនីតិសម្បទា (លេខ ៦២០៩៦) និងឧបត្ថម្ភតាវកាលិកផ្សេងៗលើហានិភ័យការងារ (លេខ ៦២០៩៨)។

**២០.** គណនី "ឧបត្ថម្ភតាវកាលិកលើការថែទាំសុខភាពរបស់មន្ត្រីសាធារណៈ កម្មករ និងនិយោជិត" (លេខ ៦២១០) ប្រើសម្រាប់កត់ត្រានៅបេឡាជាតិសន្តិសុខសង្គម នូវចំនួនទឹកប្រាក់ដែលបានចំណាយថវិកាបើកផ្តល់តាវកាលិកលើការថែទាំសុខភាពតាមលិខិតបទដ្ឋាន និងលក្ខខណ្ឌ ដែលត្រូវផ្តល់ប្រាក់ឧបត្ថម្ភ។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការបើកផ្តល់ឧបត្ថម្ភតាវកាលិក

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់សំណៃសចំណាយ ដែលបានបន្ថយចំណាយថវិកានៅក្នុងឆ្នាំ

- កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**បញ្ជាក់ ÷** គណនីលេខ ៦២១០ ចែកចេញជាអនុគណនី÷ ឧបត្ថម្ភលើការថែទាំឬព្យាបាលសុខភាព (លេខ ៦២១០១) ឧបត្ថម្ភមាតុភាព (លេខ ៦២១០២) ឧបត្ថម្ភប្រាក់បំណាច់ប្រចាំថ្ងៃ (លេខ ៦២១០៣) ឧបត្ថម្ភសេវាបុននីតិសម្បទា (លេខ ៦២១០៤) និងឧបត្ថម្ភលើការថែទាំសុខភាពផ្សេងៗ (លេខ ៦២១០៨)។

**២១.** គណនី "ឧបត្ថម្ភតាវកាលិកលើសោធនរបស់កម្មករនិងនិយោជិត" (លេខ ៦២១១) ប្រើសម្រាប់កត់ត្រានៅបេឡាជាតិសន្តិសុខសង្គម នូវចំនួនទឹកប្រាក់ដែលបានចំណាយថវិកាបើកផ្តល់តាវកាលិក លើសោធនតាមលិខិតបទដ្ឋាន និងលក្ខខណ្ឌ ដែលត្រូវផ្តល់ប្រាក់ឧបត្ថម្ភ។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការបើកផ្តល់ឧបត្ថម្ភតាវកាលិក

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់សំណៃសចំណាយ ដែលបានបន្ថយចំណាយថវិកានៅក្នុងឆ្នាំ

- កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយ-បរិច្ឆេទ។

**បញ្ជាក់** ÷ គណនីលេខ ៦២១១ ចែកចេញជាអនុគណនី÷ ឧបត្ថម្ភសោធនជរាភាព (លេខ ៦២១១១) ឧបត្ថម្ភវិភាជន៍បូជាសព (លេខ ៦២១១២) ឧបត្ថម្ភឧត្តរជីវី (លេខ ៦២១១៣) ឧបត្ថម្ភសោធនទព្វលភាព (លេខ ៦២១១៤) និងឧបត្ថម្ភលើសោធនផ្សេងៗ (លេខ ៦២១១៨)។

**២២.** គណនី "ឧបត្ថម្ភកញ្ចប់គ្រួសារ" (លេខ ៦២១២) ប្រើសម្រាប់កត់ត្រានៅមូលនិធិជាតិជំនួយសង្គម នូវចំនួនទឹកប្រាក់ដែលបានចំណាយថវិកាផ្តល់ឧបត្ថម្ភលើកម្មវិធីជាតិជំនួយសង្គម ដោយយោងតាមលិខិតបទដ្ឋាន និងលក្ខខណ្ឌ ដែលត្រូវផ្តល់ប្រាក់ឧបត្ថម្ភ។

ការកត់ត្រា÷

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើការឧបត្ថម្ភកម្មវិធីជាតិជំនួយសង្គម

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់សំណៃសចំណាយ ដែលបានបន្ថយចំណាយថវិកានៅក្នុងឆ្នាំ

- កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយ-បរិច្ឆេទ។

**បញ្ជាក់** ÷ គណនីលេខ ៦២១២ ចែកជាអនុគណនី÷ ឧបត្ថម្ភស្ត្រីមានផ្ទៃពោះ (លេខ ៦២១២១) ឧបត្ថម្ភមនុស្សចាស់ (លេខ ៦២១២២) ឧបត្ថម្ភកុមារក្នុងសាលារៀន (លេខ ៦២១២៣) និងឧបត្ថម្ភគាំពារសង្គមផ្សេងៗ (លេខ ៦២១២៨)។

**២៣.** អនុគណនី "ឧបត្ថម្ភធន ឬ បែងចែកចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដល់ក្រសួង ស្ថាប័ន" (លេខ ៦៥០១៤) ប្រើសម្រាប់កត់ត្រានៅរដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងនៅគ្រឹះស្ថានសាធារណៈរដ្ឋបាល នូវចំនួនទឹកប្រាក់ចំណាយថវិកាលើការផ្តល់ឧបត្ថម្ភធនដល់ក្រសួង ស្ថាប័ន ឬ ការចំណាយថវិកាលើការបែងចែកចំណូលដែលគ្រឹះស្ថានសាធារណៈរដ្ឋបាលប្រមូលបាន ជូនក្រសួង ស្ថាប័ន ឬ អង្គភាពផ្សេងៗ តាមការសម្រេច ឬ គោលការណ៍កំណត់របស់ក្រសួងអាណាព្យាបាលបច្ចេកទេស ឬ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការកត់ត្រា

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ឬ អង្គភាពបានចំណាយថវិកាជូនក្រសួង ស្ថាប័ន ឬ អង្គភាពផ្សេងៗ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ ដែលបានចំណាយថវិកាផ្តល់ឧបត្ថម្ភធនជូនក្រសួង ស្ថាប័ន ឬ អង្គភាព ហើយបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លូកបន្តដែលពុំទាន់ផ្ទេរទៅគណនីលទ្ធផលនៃការិយ-បរិច្ឆេទ។

២៤.គណនី "ចំណូលកាតព្វកិច្ចពីល្បែង និងកម្រៃប្រតិបត្តិការផ្សេងៗ" (លេខ ៧៣០៦) ប្រើសម្រាប់កត់ត្រានៅរដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងរតនាគារ នូវចំនួនទឹកប្រាក់ចំណូលថវិកា ដែលបានពីកាតព្វកិច្ចពីល្បែងកាស៊ីណូ កាតព្វកិច្ចពីល្បែងផ្សងសំណាង និងកាព្វកិច្ចពីល្បែងភ្នាល់តាមលិខិតបទដ្ឋានដែលបានកំណត់ជាធរមាន។

ការកត់ត្រា

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានពីល្បែង និងពីកម្រៃនៃប្រតិបត្តិការផ្សេងៗ ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានពីកាតព្វកិច្ចពីល្បែង និងពីកម្រៃប្រតិបត្តិការផ្សេងៗ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាប្លូកបន្តដែលពុំទាន់ផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**បញ្ជាក់ ÷** គណនីលេខ ៧៣០៦ ចែកជាអនុគណនី÷ ចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូ (លេខ ៧៣០៦១) ចំណូលកាតព្វកិច្ចពីល្បែងផ្សងសំណាង (លេខ ៧៣០៦២) ចំណូលកាព្វកិច្ចពីល្បែងភ្នាល់ (លេខ ៧៣០៦៣) ចំណូលពីអាជ្ញាប័ណ្ណនាំចេញ (លេខ ៧៣០៦៤) ចំណូល ពីអាជ្ញាប័ណ្ណក្នុងស្រុក (លេខ ៧៣០៦៥) និងកម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ (លេខ ៧៣០៦៧)។

**ប្រការ៤.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.–**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានស្ថាប័នរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៣ រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០២២

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

 *"ដើម្បីជូនជ្រាប"*

- ដូចប្រការ៥

 *"ដើម្បីអនុវត្ត"*

- ឯកសារ-កាលប្បវត្តិ